# អគ្គលេខាធិការអង្គការសហប្រជាជាតិ
# សេចក្តីប្រកាសព័ត៌មាន

**នាយកដ្ឋានព័ត៌មានសាធារណៈ ផ្នែកព័ត៌មាននិងបណ្តាញផ្សព្វផ្សាយ ញូវយ៉ក**

SG/SM/10399
**ថ្ងៃ៣០ មិនា ២០០៦**

## អគ្គលេខាធិការអង្គការសហប្រជាជាតិព្រួយបារម្ភចំពោះប្រសាសន៍របស់លោកនាយករដ្ឋមន្ត្រីប្រទេសកម្ពុជា លើការងារនៃមន្ត្រីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ

សេចក្តីថ្លែងការណ៍ខាងក្រោមនេះចេញដោយអ្នកនាំពាក្យរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ មានការព្រួយបារម្ភចំពោះការវាយតម្លៃនាពេលថ្មីៗនេះរបស់លោកនាយករដ្ឋមន្ត្រីប្រទេសកម្ពុជាទៅលើការងាររបស់តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស រួមទាំងការងាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា។

លោកអគ្គលេខាធិការរំលឹកឡើងវិញថា អាណត្តិនៃតំណាងពិសេស និង ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៣ ដោយសហគមន៍អន្តរជាតិតាមរយៈគណៈកម្មការសិទ្ធិមនុស្សនិងមហាសន្និបាតអង្គការសហប្រជាជាតិដើម្បីតាមដាននូវ ការគោរពសិទ្ធិមនុស្ស និងសេរីភាពសំខាន់ៗនានា រួមទាំងជួយគាំទ្ររដ្ឋាភិបាល និង ប្រជាពលរដ្ឋកម្ពុជាក្នុងការធានាអោយមានការសង្កេតការណ៍ទៅលើនិយាមសិទ្ធិមនុស្សនានា ដែលទទួលស្គាល់ដោយរដ្ឋាភិបាល។ អាណត្តិនេះត្រូវបានបន្តដោយមានការពិគ្រោះយោបល់ជាមួយនឹងរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ នេះបង្ហាញអោយឃើញនូវការ ទទួលស្គាល់របស់ភាគីទាំងពីរ ទៅលើតម្រូវការជាបន្ត នូវការងារសិទ្ធិមនុស្សដ៏មានសារៈប្រយោជន៍នេះ នៅក្នុងប្រទេសកម្ពុជាក៏ដូចជាតម្រូវការនូវវិភាគទាននានាដែលផ្តល់ដោយតំណាងពិសេសផ្សេងៗរួមទាំងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលកំពុងបំពេញកាតព្វកិច្ច របស់ពួកគេដោយ ឯករាជ្យ សុចរិត និងជំនាញច្បាស់លាស់។

លោកអគ្គលេខាធិការ ជឿជាក់ថា រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជានឹងបន្តនូវកិច្ចសហប្រតិបត្តិការណ៍របស់ខ្លួនជាមួយនឹងតំណាងពិសេស រួមទាំងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា។